**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ពុធ ១៤រោច ខែ អាសាឍ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០២២*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០

នាព្រឹកថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០២២, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋ-មន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) បានដឹកនាំកិច្ចប្រជុំ គ.ស.ហ. ពិភាក្សាលើ **«សេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០»** ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងពាណិជ្ជកម្ម, ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួង-ស្ថាប័នពាក់ព័ន្ធដទៃទៀត ។

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ការធ្វើពិពិធកម្មសេដ្ឋកិច្ចជាអាទិភាព ដោយផ្តោតលើការអភិវឌ្ឍវិស័យគន្លឹះៗ ដែលក្នុងនោះ វិស័យប្រៃសណីយ៍ ត្រូវបានចាត់ទុកថាមានសក្តានុពលខ្ពស់ ក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចដោយផ្ទាល់ តាមរយៈការបង្កើតការងារ ក្នុងវិស័យប្រៃសណីយ៍ និងដោយប្រយោល តាមរយៈការទ្រទ្រង់ដល់វិស័យដទៃទៀត ជាពិសេស ចូលរួមចំណែកទ្រទ្រង់ការអភិវឌ្ឍពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក (e-commerce), គាំទ្រដល់ពិពិធកម្មសេដ្ឋកិច្ចកម្ពុជា និងជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាបន្ន ។

ទោះបីជាយ៉ាងនេះក្តី, ការអភិវឌ្ឍវិស័យប្រៃសណីយ៍នៅកម្ពុជា នៅមានកម្រិតនៅឡើយ ដោយវិស័យនេះងាយទទួលរងផលប៉ះពាល់ពីកត្តាខាងក្រៅ និងមានប្រភពចំណូលនៅតូចចង្អៀត ហើយវិសាលភាពនៃការផ្តល់សេវាក៏មិនទាន់បានទូលំទូលាយ ។ ការណ៍នេះ បណ្តាលមកពីបញ្ហាប្រឈមចម្បងៗមួយចំនួន ដូចជា ៖ ការខ្វះខាតបទដ្ឋានគតិយុត្ត, ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, បណ្តាញប្រៃសណីយ៍, ការធ្វើពិពិធកម្ម និងទំនើបកម្មសេវាប្រៃសណីយ៍, យន្តការគ្រប់គ្រងការធ្វើអាជីវកម្មរបស់ផ្នែកឯកជន, យន្តការលើកកម្ពស់គុណភាពនៃការផ្តល់សេវា និង ប្រព័ន្ធអេកូ-ឡូហ្ស៊ីឌីជីថល ជាដើម ។

ក្នុងន័យនេះ, ក្នុងគោលដៅធ្វើឱ្យវិស័យប្រៃសណីយ៍ សម្រេចបាននូវសក្តានុពលពេញលេញជាវិស័យចូលរួមចំណែកគាំទ្រពិពិធកម្មសេដ្ឋកិច្ចកម្ពុជា, ការរៀបចំ **«គោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០»** គឺជាកិច្ចការចាំបាច់ ដែលនឹងដើរតួនាទីជាប្រទីបនាំផ្លូវឆ្ពោះទៅរកការឆ្លើយតប និងដោះស្រាយបញ្ហាប្រឈមខាងលើ ក៏ដូចជា ការចាប់យកប្រយោជន៍ឱ្យបានជាអតិបរមាពីកាលានុវត្តភាព និងកត្តាអំណោយផល ដែលបាន និងកំពុងលេចឡើងពីនិន្នាការបច្ចុប្បន្ន ដូចជា ៖ ការរីកចម្រើននៃសង្គម-សេដ្ឋកិច្ច, ការវិវឌ្ឍយ៉ាងឆាប់រហ័សនៃ

បច្ចេកវិទ្យា និង ការកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិត, ចំនួនអ្នកប្រើប្រាស់បណ្តាញសង្គម និងសេវាហិរញ្ញវត្ថុតាមប្រព័ន្ធអេឡិច-ត្រូនិក ព្រមទាំងវឌ្ឍនភាពនៃវិស័យផ្សេងទៀត និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តតភ្ជាប់ក្នុងប្រទេស ។

ជាមួយនឹងកិច្ចពិភាក្សា, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំ បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលបានរៀបចំ **«សេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០»** ដ៏មានសារៈសំខាន់នេះឡើង និងក៏ដូចជាចំពោះថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា និងផ្តល់ជាតុចូល ដើម្បីកែលម្អសេចក្តីព្រាងគោលនយោបាយនេះ ឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយបន្ថែមទៀត និងបានស្នើឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ បន្តសហការប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីអាចបញ្ចប់ការរៀបចំកិច្ចការដ៏មានសារៈសំខាន់នេះ ឱ្យបានឆាប់រហ័ស ។